**កម្មវត្ថុ៖ កិច្ចប្រជុំក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន ដោយផ្ទាល់ និងមានជម្រើសតាមអនឡាញ – ថ្ងៃទី 13 ខែសីហា ឆ្នាំ 2026**

ភាគីពាក់ព័ន្ធយុត្តិធម៌បរិស្ថានទាំងអស់ជាទីគោរព!

ការិយាល័យប្រតិបត្តិកិច្ចការថាមពលនិងបរិស្ថាន (EEA) សូមកោះអញ្ជើញក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន (EJC) ដើម្បីចូលរួមក្នុងកិច្ចប្រជុំបន្ទាប់របស់ខ្លួននៅ**ថ្ងៃទី 13 ខែ**សីហា **ឆ្នាំ 2026 វេលាម៉ោង 6:30 ល្ងាច (ម៉ោង EST)**។ សមាជិកក្រុមប្រឹក្សានឹងពិភាក្សាអំពី អំពីមជ្ឈមណ្ឌលទិន្នន័យ។ ផ្នែកជាក់លាក់មួយនៃកិច្ចប្រជុំនឹងត្រូវបម្រុងទុកសម្រាប់មតិយោបល់ទូទៅពីសាធារណជន។

**សូមចុះឈ្មោះសម្រាប់កិច្ចប្រជុំតាមរយៈតំណភ្ជាប់នេះ៖**
[https://www.zoomgov.com/webinar/register/WN_qhJlC54oSiyc0EQf4c3BOg](https://www.zoomgov.com/webinar/register/WN_qhJlC54oSiyc0EQf4c3BOg)

**ការរៀបចំកិច្ចប្រជុំ៖** នឹងធ្វើឡើងដោយផ្ទាល់នៅឯ First Congregational Church ហើយក៏មានជម្រើសចូលរួមតាមរយៈ Zoom ផងដែរ។ កិច្ចប្រជុំនេះត្រូវបានប៉ាន់ស្មានថានឹងមានរយៈពេល ៩០ នាទី។ អគារនេះមានទីតាំងស្ថិតនៅលេខ 4 Main Street, Stockbridge, MA 01262។ លោកអ្នកអាចធ្វើដំណើរទៅទីនោះបានដោយជិះរថយន្តក្រុងលេខ 921។ មានកន្លែងចតរថយន្តសម្រាប់អ្នកចូលរួម។ សូមចំណាំ៖ ទីតាំងនៃកិច្ចប្រជុំត្រូវបានផ្លាស់ប្តូរ។

**ជំនួយផ្នែកបកប្រែ៖** ការបកប្រែតាមប្រព័ន្ធ Zoom រួមមាន ភាសាអេស្ប៉ាញ ភាសាព័រទុយហ្គាល់ ប្រេស៊ីល ភាសាចិនកុកងឺ ភាសាគ្រីអូលហៃទី ភាសាវៀតណាម និងភាសាគ្រីអូលកាប់វែរនឹងមានផ្តល់ជូនតាមអនឡាញតាមប្រព័ន្ធ Zoom។ នឹងមានផ្តល់ជូនការបកប្រែផ្ទាល់មាត់ជាភាសា អេស្ប៉ាញ ដោយផ្ទាល់។ ប្រសិនបើអ្នកត្រូវការការបកប្រែផ្ទាល់មាត់ជាភាសាផ្សេងទៀត ការស្នើសុំត្រូវតែដាក់ជូនរយៈពេល 48 ម៉ោងមុនពេលវេលាចាប់ផ្តើមកិច្ចប្រជុំ។ ការសម្របសម្រួលបន្ថែមណាមួយ រួមទាំងសេវាកម្មភាសាសញ្ញាអាមេរិក (ASL) នឹងមានផ្តល់ជូនតាមការស្នើសុំ។ ដើម្បីស្នើសុំការសម្របសម្រួលបន្ថែម រួមទាំង ASL សូមបញ្ចូលសំណើនោះក្នុងអ៊ីមែលទៅកាន់ [meetings@erg.com](mailto:meetings@erg.com)។ សំណើសុំ ASL ត្រូវតែដាក់ជូនរយៈពេលបីសប្តាហ៍មុនពេលកិច្ចប្រជុំចាប់
ផ្តើម។

ដើម្បីទទួលបានព័ត៌មាននេះជាភាសាអង់គ្លេស អក្សរពុម្ពធំ ឬអក្សរស្ទាបសម្រាប់មនុស្សពិការភ្នែក សូមហៅទូរសព្ទទៅលេខ 1-877-623-6765។ TTY៖ 1877-623-7773។

**ច្បាប់ប្រជុំដោយបើកចំហ៖** ក្រុមប្រឹក្សា EJ ប្រតិបត្តិការក្រោមច្បាប់ប្រជុំដោយបើកចំហ [[https://www.mass.gov/the-open-meeting-law](https://www.mass.gov/the-open-meeting-law)] ហើយស្វាគមន៍សមាជិកសាធារណជនទាំងអស់ដែលមានបំណងចង់ចូលរួមសង្កេតកិច្ចប្រជុំផ្លូវការរបស់ខ្លួន។

**ព័ត៌មានបន្ថែមអំពីក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន** (EJC)៖ EJC គឺជាក្រុមប្រឹក្សាដែលត្រូវបានតែងតាំងដោយអភិបាលដើម្បីផ្តល់យោបល់ និងផ្តល់អនុសាសន៍ដល់រដ្ឋមន្ត្រី EEA អំពីគោលនយោបាយ និងស្តង់ដាដែលពាក់ព័ន្ធ ដើម្បីសម្រេចបាននូវគោលការណ៍យុត្តិធម៌បរិស្ថាននានា។ គោលការណ៍ទាំងនេះត្រូវបានកំណត់ដោយច្បាប់របស់រដ្ឋថាជា “គោលការណ៍ដែលគាំទ្រការ

ការពារពីការបំពុលបរិស្ថាន និងលទ្ធភាពក្នុងការរស់នៅក្នុងបរិស្ថានស្អាត និងមានសុខភាពល្អ ដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ ប្រាក់ចំណូល វណ្ណៈ ពិការភាព អត្តសញ្ញាណយេនឌ័រ ទំនោរផ្លូវភេទ ដើមកំណើតជាតិ ជាតិសាសន៍ ឬពូជពង្ស ជំនឿសាសនា ឬជំនាញភាសាអង់គ្លេស ដែលរួមមាន៖ (i) ការចូលរួមយ៉ាងសកម្មរបស់ប្រជាជនទាំងអស់ពាក់ព័ន្ធនឹងការអភិវឌ្ឍ ការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់ បទបញ្ញត្តិ និងគោលនយោបាយបរិស្ថាន ដោយរួមទាំងគោលនយោបាយស្តីពីបម្រែបម្រួលអាកាសធាតុ និង (ii) បំណែងចែកប្រកបដោយសមធម៌នូវថាមពលនិងផលប្រយោជន៍បរិស្ថាន ព្រមទាំងបន្ទុកបរិស្ថាន។” ច្បាប់នេះត្រូវបានចែងត្រង់ផ្នែក 62L ក្នុងតំណនេះ៖
[https://malegislature.gov/Laws/SessionLaws/Acts/2021/Chapter8]។

ព័ត៌មានបន្ថែមអំពី EJC កិច្ចប្រជុំនាពេលខាងមុខ និងសំឡេងថតកិច្ចប្រជុំកន្លងមក អាចរកបាននៅទីនេះ៖ https://www.mass.gov/orgs/environmental-justice-council ។ សូមចុចលើពាក្យ “Select Language” នៅខាងលើផ្នែកខាងស្តាំនៃគេហទំព័រ ដើម្បីបកប្រែទំព័រនេះ។

សូមអរគុណ!

María Belén Power
អនុរដ្ឋមន្ត្រីសមធម៌និងយុត្តិធម៌បរិស្ថាន
ការិយាល័យប្រតិបត្តិកិច្ចការថាមពលនិងបរិស្ថាន